«ខ្ញុំមានអារម្មណ៍អត់សូវល្អទេថ្ងៃនេះ បងមីន! មេនសាទៅស្រុកបាត់ហើយ ម្ដាយនាងឈឺ!» មេរូខលទៅនិយាយនឹងបងប្រុស។

«បងដឹងហើយ! ឮសូរថាគាត់ខូចបាត់ហើយ!» មីនតបមកវិញទាំងទំពាបាយផង។

«ថាម៉េច? ម៉េចចឹងបងមីន? ខ្ញុំទើបតែងូតទឹកមុនសោះហ្នឹង?»

«គាត់ស្លាប់ពាក់ព័ន្ធអីនឹងឯងងូតទឹក?»

«ចង់និយាយថា....ហើយលឿនម្ល៉េះ? ដំណឹងហ្នឹង? មេនសាមិនទាន់ទៅដល់ស្រុកផងដឹង?»

«នៅ! ប៉ុន្តែគេទាក់ទងមកបងមុននេះ ប្រាប់រឿងនេះ!»

មេរូដៀងមកសម្លឹងទូរសព្ទខ្លួនឯង។

«ប្រហែលជាគេទូរសព្ទមកខ្ញុំអត់លើកដឹងបានខលទៅបងឯង? ខ្ញុំអាល័យទៅងូតទឹក!»

ភ្លាមនោះតរុណីនឹកឃើញឡើងវិញដល់អ្វីម្យ៉ាង។ សំឡេងដែលបានឮមកកាលសំងំក្នុងបន្ទប់ទឹក ជាពិសេសសំឡេងដែលនិយាយច្បាស់នឹងត្រចៀកថា មិនបាច់ទៅទេ ស្រីនោះគង់តែស្លាប់។

យឺតៗនាងបែរសម្លឹងមើលជុំវិញខ្លួន។

មេឃនៅខាងក្រៅធ្លាក់ភ្លៀងប្រុយៗលាន់សូរមកប៉ះលើបង្អួចកញ្ចក់។

ដៃម្ខាងកាន់ទូរសព្ទមេរូដើររកបង្អួចមួយនេះទៀត នឹងអាលមើលដឹងថាបិទជិតឬនៅ មាត់ក៏នៅនិយាយទៅរកបងជីដូនមួយ៖

«បើមិនរវល់អីទេ មកគេងលើនៅនេះបានអត់?»

«ដាច់ចិត្តសារភាពថាខ្លាចខ្មោចហើយ?»

«មានអារម្មណ៍មិនសូវល្អបានជាខលទៅ!»

«អើ ប្រហែលជាហត់ពេក!»

«ឮសូរសំឡេងផ្គរសង្កាសដល់ហើយ!»

«បានហើយ ដេកលេងសិនទៅ!»

«មកឬអត់?!»

«ចាំមើលសិន!»

«ម៉ោៗណ៎ា ខ្លាចតាស់!»

«ហ្អើយ! យាយ! ថាឲ្យញយហើយ រឿងទៅកន្លែងបុរាណៗកុំសូវយកចិត្តទុកដាក់ ទៅស្ដាប់ពួកមគ្គុទេសក៍អស់នោះនិយាយរឿងពីព្រេងអីទាំងអស់ហ្នឹងពេក គ្មាននរណាគេដឹងថាពិតឬក៏មិនប្រតិដ្ឋរកលុយទេ! ដឹងតែថា ពួកគេហ្នឹងធ្វើដូចជាពិតណាស់អ៊ីចឹង ធ្វើឱ្យខ្លាចរួញអស់មួយបាត់ឃើញអត់?»

«សម្រេចថាមកឬក៏អត់ និយាយច្រើនណាស់ នាំមនុស្សព្រឺសម្បុរ!»

«ណាត់គេញ៉ាំអីហើយ!»

«គេណ៎ា សង្សារហ្មែន!»

«ចាំបាច់ប្រាប់ឯងដែរ? ឥឡូវនេះរកអីញ៉ាំសិន ឬមើលទូរទស្សន៍មើលអីលេងហ្វេសប៊ុកអ៊ីចឹងទៅ បងញ៉ែគេបានហើយ ចាំទៅដេកកំដរក៏បាន!»

«កុំភ្លេចសម្ដី កុំកុហកព្ទនៅ?»

មេរូដាក់ទូរសព្ទចុះរាងធូរចិត្តដែរពេលឮបងប្រាប់ថា អាចពួកអ្នកតំណាលរឿងព្រេងបោកក្មេងយកលុយទេ។ នាងដើរទៅចង្ក្រានបើកទូទឹកកកយកបន្លែសាច់ ត្រៀមថាឆាបាយមួយចានកម្ដៅពោះ ប៉ុន្តែគ្មានបាយនោះទេដូច្នេះនាងត្រូវដាំបាយសិន។

នៅពេលកំពុងរង់ចាំបាយឆ្អិន មេរូបានចិតបន្លែនិងហាន់សាច់ទុកជាស្រេចរួចទើបនាងដើរមុនមកអង្គុយចុចទូរទស្សន៍មើល។

ភ្លៀងនៅខាងក្រៅបង្អុរខ្លាំងខ្វរឡើងៗ រហូតដល់ថ្នាក់តួស្រីម្នាក់នេះចាប់អារម្មណ៍ភ័យថាៜ មីនមិនដឹងជិះមកដោយរបៀបម៉េចផងទេ។

មេរូដើរទៅជិតបង្អួចរកចាំផ្លូវបងប្រុស តែភ្លៀងនិងទឹកព្រមទាំងចំហាយស្រអាប់ត្រជាក់បានបិទបាំងសូម្បីតែផ្លូវខាងក្រៅក៏មើលលែងឃើញ។

ស្រីនិស្សិតថយមកអង្គុយលើសាឡុងទាំងចាប់អារម្មណ៍រងា។

មេរូនឹកចង់បានភួយមួយយកមកដណ្តប់ ប៉ុន្តែពេលក្រឡេកទៅបន្ទប់គេងកាលណា ទីកន្លែងដែលនាងធ្លាប់មានវត្ថុមានមេនសា ពេលនេះបែរជាមិនហ៊ានដើរទៅយកភួយសោះ។

តាមថា អាផាតមិនមួយនេះតូចណាស់ហើយសម្លឹងផ្ទះជញ្ជាំងម្ខាងដល់ម្ខាង។ វាពិតជាមិនគួរឲ្យខ្លាចទេ វាតូចត្រឹមមានកូនបន្ទប់បាយ បន្ទប់មើលទូរទស្សន៍និងបន្ទប់គេងតូចមួយប៉ុណ្ណោះ ប៉ុន្តែហេតុអ្វីយប់នេះមានអារម្មណ៍ដូចជាមិនសូវស្រួល?

ម្ចាស់បន្ទប់ឱបដៃរេមករកទាញស្រោមជើងមួយគូថ្មីពីថតតុ មកពាក់បន្ថែមនិងទម្រេតខ្លួនទុកឲ្យទូរទស្សន៍មើលនាងវិញ ដោយស្លុងគេងលក់ទៅក្នុងភាពត្រជាក់របស់រាត្រីកាលទាំងភ្លេចចោលការស្រេកឃ្លាន។

មេរូ! មេរូ!

សំឡេងខ្សឹបហៅបង្អូសៗនៅក្បែរៗត្រចៀក ជាសំឡេងមនុស្សប្រុស។ ហៅរហូតមិនឈប់សោះ ដូចRobot មិនចេះហត់មាត់ដែលហៅសោះ?

មេរូរំខានចិត្ត ណាមួយនាងពិតជាចង់ឆ្លើយតប ប៉ុន្តែឆ្លើយមិនរួចព្រោះស្លុងទៅក្នុងដំណេកល្វើយឆ្ងាយ។ មិនដឹងជាហេតុអ្វីបានជាលក់អីលក់កម្រិតនេះ។

ស្រាប់តែភ្លាមនោះ វត្ថុត្រជាក់មួយបានប៉ះចុងជើង រហូតដល់កំភួនជើង ឡើងប៉ះដល់ជង្គង់ប៉ះភ្លៅ ត្រជាក់ប៉ះដល់ចង្កេះ ហើយចុងក្រោយប៉ះទ្រូង។

មេរូនាងមានអារម្មណ៍ថាខ្លួនឯងកំពុងគេងនៅក្នុងអាងហែលទឹក។

មាណវីស្រីបើកភ្នែកខ្វាកភ្ញាក់ដឹងខ្លួនឡើងមកវិញជាមួយនឹងសំឡេងទឹកហូរយ៉ាងគំហុកបរិយាកាសអាប់អួរ ដូចសន្ទឹកព្យុះព្យុះសង្ឃរានៅក្នុងរឿងហូលីវូដដែលនាងតែងតែបានឃើញផែនដីបាក់ហើយទឹកលិចពាសពេញផែនដី។

អុញ! ផ្ទះលិចទឹកអីកម្ពស់នេះ?

ស្រស់ស្រីចង់ស្ទុះក្រោក ប៉ុន្តែទំនាញទឹកបានសង្កត់នាងឲ្យអង្គុយចុះមកលើសាឡុងវិញភ្លាមដោយតក់ស្លុត។ មេរូទាំងស្លន់ស្លោព្រោះទឹកបានលិចដោយទ្រូងនាងខំប្រមូលស្មារតីគិតថាតើជាយល់សប្តិឬមួយក៏មែនទែន?

ទឹកភ្លៀងលិចពេញផ្ទះ អ្នកណាបើករ៉ូប៊ីណេចោល? ហេតុអីទៅ? មានរឿងអីកើតឡើង? នាងខំប្រវេប្រវាក្រោកទៀតដែរ ជាមួយនឹងការចៃវផងច្រត់ផង អូសទាញយោងកាយខ្លួនឯងឲ្យ

បានក្រោកឈរឡើង ហើយសរសៀរៗដោយលំបាកសំដៅទៅរកទ្វារ ប៉ុន្តែទៅមិនកើតទេ ណាមួយមើលពីនេះទៅ ទ្វារជាប់ម៉ឺងទៅហើយ។

មេរ្ហូចសម្លឹងពីនេះទៅក៏ដឹងដែរថា កម្លាំងទឹកហូរក្នុងកម្ពស់បែបនេះតើនាងបើកទ្វារចេញម្ដេចនឹងកើតទៅ?

ខាងក្រៅលិចលង់កម្រិតណា បានជាពីក្នុងផ្ទះមិនអាចបង្ហូរទឹកចេញទៅសោះ?

ពុទ្ធោយើងឆ្កួតហើយឬក៏អី? នេះជាអាផាតមិនជាន់ទី៦ ហេតុអ្វីមានទឹកជន់លិចបានខ្ពស់ម្ល៉េះ? នាងថយទៅកាន់ជញ្ជាំងទប់ប្រាណផ្អែក ទាំងយំមិនចេញ ស្រែកមិនកើត។ រាងកាយទាំងមូលកំពុងគ្រប់គ្រងទៅដោយរលកទឹក។

«រឿងអីកើតឡើង? ជួយខ្ញុំផង? ជួយខ្ញុំផង? អ្នកណាឮខ្ញុំជួយផង!»

នាងស្រែកក្នុងចិត្តប៉ុន្តែមាត់មិនបានបញ្ចេញសំឡេងនោះទេ។

«ខ្ញុំសុំអង្វរឲ្យជួយខ្ញុំផង!»

ពេលនេះ នាងក៏ទន់ខ្លួនចុះ សន្លប់ឈឺងរបូតជំហរធ្លាក់រាងកាយទាំងមូលទៅក្នុងកម្រាលកម្ពស់ទឹក ទាំងខួរក្បាលនៅរិះគិតមិនឈប់ដូច្នេះថា «យើងនឹងស្លាប់មិនខាន! យើងនឹងដេកយ៉ាងដូច្នេះ! ហើយលេបទឹករហូតដាច់ដង្ហើម គ្មានអ្នកណាដឹងយើងសូម្បីពេទ្យមិនអាចជួយយើងបានទេ! គ្មានអ្វីអាចតតាំងទៀតឡើយ!»

មិនយូរទេ សំឡេងមីនស្រែកហៅមកពីចម្ងាយ។ មេរ្ហូដែលអណ្ដែតចុះឡើងក្នុងស្រទាប់ទឹកនាងអរណាស់ អរក្រៃណានឹងអរ ក៏ចង់ឆ្លើយទៅណាស់ ក៏ឆ្លើយមិនរួច ប្រឹងហើយប្រឹងតបទៀតយ៉ាងណា សណ្ឋានបំពង់កហាក់រឹងត្អឹងណែនទ្រូងង៉ាង។

មេរ្ហូខំប្រឹងមួយទំហឹងចុងក្រោយដើម្បីស្រែកឆ្លើយតបថា «ជួយផង» ការទម្លាយចេញបាន២ម៉ាត់នេះ ធ្វើឲ្យនាងដណ្ដើមបានខ្យល់ដង្ហើមខ្លួនឯងមកវិញ ស្រវាក្រោកឡើងទាំងច្របូកច្របល់ញ័រសាច់។

មេរ្ហូស្រាប់តែឃើញខ្លួនឯងស្ថិតនៅលើសាឡុងទៅវិញ?

គ្រប់យ៉ាងជុំវិញស្ងួតច្រើងមិនមានទឹកលិច ដូចដែលនាងទើបនឹងឃើញស្ទើរបង់សង្ខារនោះទេ។ ប៉ុន្តែសំឡេងដង្ហោយហៅរបស់មីនគឺជាការពិត គេនៅហើយទ្វារនៅឡើយ គេគោះទ្វារផងស្រែកផង។

ទាំងសើងមម៉ើងនិងសែនល្ងើយកម្លាំងកាយសាបមាត់ឈឹងដូចមនុស្សឈឺ មេរូប្រឹងក្រោកឡើងដើរយ៉ាងលឿនទៅរកទ្វារ ហើយបើកទ្វាររួចស្រវាឱបបងប្រុសណែនដៃ។

«ខ្ញុំយល់សប្តិអាក្រក់ណាស់!»

អ្វីមួយដាក់មកច្បាមចំលើកញ្ចឹងកនាងពីក្រោយ។ មានអារម្មណ៍ថា ជាដៃរបស់មីនដែលទាញច្បាមមិនឱ្យនាងឱបនិងឮសំឡេងខ្សឹបដាក់ត្រចៀកថា «លែងភ្លាមកុំឱបមនុស្សប្រុស»។

មេរូមិនបានមិនឃើញមុខមីនទេ ព្រោះជាប់ដាក់ក្បាលលើស្មារបស់គេ ប៉ុន្តែសំឡេងនេះប្រាកដណាស់មិនមែនសំឡេងរបស់មីនដាច់ខាត។

រីឯក្រញាំដៃដែលប៉ះកញ្ចឹងក នាងពិតជាធំនិងកាចសាហាវ ដូចជាក្រញាំរបស់មនុស្សដែលមានមាឌធំជាងមីននេះឆ្ងាយ។

នាងពន្លែងកាយបង ថយក្រោយច្រើនជំហានដោយមិនដឹងខ្លួន។ មេរូគ្រវីក្បាលសម្លឹងទៅមុខមីន ឃើញបងប្រុសនេះក៏មើលមេរូហាក់ឆ្ងល់។ អាការៈនាងប្លែកណាស់ទៅហើយសម្រាប់ឱ្យមីនយល់។ នាងហាក់ខ្លាចអ្វីមួយអាថ៌កំបាំង។ មាត់នាងញ័រ ទឹកមុខឆ្ងល់ដូចគ្នាបេះបិទនឹងបងមីនរបស់នាងដែលឆ្ងល់ឡើងៗ។

«ម៉េចហ្នឹង? ហើយឱ្យហៅទ្វារយូរម៉េះ? គេងហ្មែន?»

នាងរកបកស្រាយអ្វីមិនកើត ក៏ឆ្លើយមិនចេញ។ មេរូចង់ប្រាប់មីនទាំងអស់ពីរឿងយល់សប្តិឃើញទឹកលិចផ្ទះពេញបន្ទុក ប៉ុន្តែគ្រាន់បើហើយដែលក្រោយមកវាស្ងួត ចុះហេតុអីបានជាអម្បាញ់មិញនេះមាននរណាម្នាក់ច្បាមកាន់កញ្ចឹងកពីក្រោយហើយថែមទាំងបង្អាក់នាងមិនឲ្យឱបមីនទៀត។

នាងមើលទៅដៃទាំងសង មីនកំពុងតែជាប់កាន់ឃ្នរស្បោងពីរធំៗតាមរបៀបសមជាអាហារពេលយប់។ គេគ្មានដៃទីបីឯណាមកចាប់ច្បាមកញ្ចឹងកនាងទេ។

មីនដើរហួសចូលទៅរហូតដល់បន្ទប់បាយ ទុកឲ្យមេរូឈរងង្គក់ភ័យម្នាក់ឯង។

មាត់ទ្វារនៅចំហនៅឡើយ។

ស្រីដើរយឺតៗទៅក្បែរនោះរវេ្នកក្រឡេកក្រឡាប់ស្លន់សម្លឹងចុះឡើងទៅខាងក្រៅក្រែងមានអ្នកណានៅក្បែរៗនោះមុននេះ។

គ្មានទេ ស្ងាត់សូន្យ។

មេឃត្រជាក់ត្រជាក់ពេកហើយ គឺត្រជាក់ដល់ឆ្អឹង។

ការច្បាមមួយប៉ប្រិចភ្នែកមុននេះលើស្មានិងកញ្ចឹងក នៅឈឺនៅឡើយ។

«គ្មាននរណាម្នាក់ អីចឹងអ្នកណាធ្វើ?»

នាងចាប់ផ្ដើមព្រឺសម្បុរ។

មេរូបិទទ្វារគ្រាំ ផ្អើលដល់មីនឱ្យដាក់ស្លាបព្រាមួយចុះសឹងមិនទាន់ គេងាកពីតុបាយមកមើល។

«ស្អីហ្នឹង?» មីនសួរ។

មេរូដើរមកក្បែរបងប្រុសនិយាយខ្សឹបតិចៗ៖

«ហេតុអីខ្ញុំស្រមៃឃើញរឿងដែលមិនគួរ? ខ្ញុំឃើញបន្ទប់នេះលិចទឹក ហើយលង់ខ្ញុំធ្លាក់ចូល បានជាក្រោកទៅបើកទ្វារឱ្យបងឯងយឺត!»

«យល់សប្ដិតាស៎ហី?»

មីនតបធ្វើហីបែរក្រោយវិញទៅស្រាយរៀបចំអាហារ។

«ហូបអីឬនៅ? បងទិញមីឆាមក! បង្អែមទៀត!»

«ខ្ញុំមមើមមាយឮសំឡេងមនុស្សនិយាយប្លែកៗពីរដងហើយបងមីន!»

ថាហើយក៏មេរូដើរតយង៉យទាំងមិនសប្បាយចិត្តចូលបន្ទប់ទឹក។

នៅមុខឡាវ៉ាបូ នាងលើកម្រាមដៃទាំង១០របស់ខ្លួនច្បូតលាងមុខទាំងមិនយល់ខ្លួនឯងថា មួយថ្ងៃនេះមានលេបថ្នាំអ្វីខុសទៅជាប្រតិកម្មស្មារតីបានធ្ងន់ល្អម្ល៉េះ?

ស្រាប់តែចាប់អារម្មណ៍ថា អ្វីម៉្យាងមិនប្រក្រតី។

ដោយភ័យព្រួយ មេរូឱនទៅមើលស្រោមជើងដែលសើមជោក។

ទឹកមកពីណា? សើមតាំងពីពេលណា?

នាងបែរសម្លឹងជុំវិញខ្លួនដែលកម្រាលឥដ្ឋសុទ្ធតែស្ងួតច្រើង។ ទ្រូងហត់គឃូសជាមួយការប្រឹងដកដង្ហើមភ័យស្លុតយ៉ាងហត់នឿយ។ ស្រោមជើងនេះទៅបានទឹកពីណាមកសើមបាន?

ស្រីបែរមកវិញសម្លឹងខ្លួនឯងក្នុងកញ្ចក់ ខ្ញុំកំពុងយល់សប្តិទៀតឬមែនទែន?

គិតហើយ ក៏ឱនសម្លឹងស្រោមជើងខ្លួនឯងថ្មី។ ខណៈនោះចាប់អារម្មណ៍ឃើញថា កញ្ចក់នៅពីមុខខ្លួន លេចចេញរូបអ្នកណាផ្សេងម្នាក់ទៀត។

បេះដូងស្រីស្លុតគាំង នាងងើបមុខសម្លឹងរឹប ក៏ឃើញរាងកាយមនុស្សប្រុសម្នាក់នៅក្នុងកញ្ចក់ខ្មៅស្រឹល។

ស្រីថយរឹប ទប់ខ្លួនយ៉ាងលំបាកផ្អែកជញ្ជាំង ព្រោះចង់រត់ចេញក្រៅក៏ឈានមិនបាន ចង់ដួលចុះ ក៏នៅមិនទាន់ដួលចង្កេះទប់ផ្អែកង៉ាង។

រាងកាយនោះនៅដដែលក្នុងកញ្ចក់ ហាក់មិនមានមុខ គ្រប់យ៉ាងខ្មាំងទាំងអស់ ប៉ុន្តែរូបរាងនោះរឹងមាំនិងធំណាស់។ មេរូនាងភ័យញ័រចំប្រប់ ហាមាត់ស្រែកហៅបងមីនក៏ស្រែកមិនឮ ហើយក៏មិនចេញសំឡេងទៀត។

ចរន្តខួរក្បាលនាងដាក់សំណួរចេញមកសួរខ្លួនឯងថា ខ្មោចមួយនេះមែនទេ ដែលនិយាយជាមួយយើងពីរដងនោះ?

លើកទីមួយមកខ្សឹបប្រាប់ថា ម្តាយរបស់មេនសាមិនរស់ ចំណែកនៅមាត់ទ្វារអម្បាញ់មិញគេឃាត់យើងមិនឱ្យឱបបងមីន?

ស្រាប់តែរូបខ្មៅនោះ បើកភ្នែកខ្វាកចេញប្រស្រីជាគ្រាប់ត្បូងធំៗខៀវស្រងាត់សម្លឹងមុខនាងមកពីក្នុងកញ្ចក់។ ចរន្តភ្នែករបស់បិសាចប៉ះនឹងភ្នែកមេរូ បណ្តាលឱ្យស្រីនិស្សិតទន់ខ្លួនដួលសន្លប់ត្មោល។

នាងបើកភ្នែកឡើងមកវិញឃើញពិតានមន្ទីរពេទ្យនិងនាឡិកាប៉ោលនៅចុងជើងវាយទ្រនិចម៉ោងបួនភ្លឺទៅហើយ។

«មីន!»

មេរូហៅបងប្រុសដោយសំឡេងខ្សត់ខ្សោយពីព្រោះដង្ហើមដង្ហក់។

មីនបានស្ទុះក្រោកពីលើកៅអីដែលដេកកំដរអ្នកជំងឺ ដើរទើមៗមកមើលនាង។ ស្រីនិស្សិតរើដៃដែលនៅជាប់ដាក់សេរ៉ូមតោងបងប្រុសរួចសួរ៖

«នាំខ្ញុំមកមន្ទីរពេទ្យមែនទេ?»

«មិនមែនមន្ទីរពេទ្យទេ គ្លីនិកនៅជិតអាផាតមិន! យើងសន្លប់ក្នុងបន្ទប់ទឹក បងដឹងធ្វើម៉េចមានតែហៅឲ្យអ្នកជិតខាងជួយលើកឯងមកកន្លែងនេះ ពេទ្យថាឯងខ្សោយ! ញ៉ាំបាយបបរទេ បងចុះទិញ!»

«កុំៗៗៗៗកុំទៅណ៎ាឱ្យសោះ កុំទុកខ្ញុំម្នាក់ឯង!»

មីននៅភាំងៗ ពេលឃើញប្អូនស្រីភ័យរន្ធត់មិនមែនធ្វើពុតទេ។ មេរូបានទាញដៃបងប្រុសមកនិយាយប្រាប់៖

«បងមីនខ្ញុំបានឃើញខ្មោចមួយនៅក្នុងកញ្ចក់បន្ទប់ទឹក!»

បងមីនមិនបានបង្ហាញទឹកមុខដល់នាងថាជឿឬមិនជឿទេ គេអង្អែលក្បាលប្អូនហើយផ្តាំ៖

«ខ្មោចស្អី! អ៊ំស្រីជិតមកដល់ហើយ!»

«បងមីនខលប្រាប់ម្តាយខ្ញុំមែនទេ?!»

«បើមិនប្រាប់គាត់ហើយក៏ត្រូវបងនៅកំដរឯងសន្លប់អ៊ីចឹងរហូតទៅ ស្អែកបងមានបេសកកម្មចុះខេត្តផង!»

«សុំទោសដែលរំខានបងឯង!»

«អ្ហីយ  ឯងធ្វើស្អីខ្លះ អត់បាយសម្រកទម្ងន់បានទៅដល់ថ្នាក់សន្លប់?!»

មីនរៀបបែរទៅវិញ មេរូតោងដៃពន្យល់ដោយមិនអស់ចិត្ត៖

«បងមីន! ស្តាប់ខ្ញុំផង ទាំងអស់នេះជាការពិត! ខ្ញុំឮសំឡេងពីរដងហើយ គឺសំឡេងមនុស្សប្រុស! លើកទីមួយបាននិយាយប្រាប់ខ្ញុំឲ្យដឹងមុនពីរឿងម្តាយរបស់មេនសានឹងស្លាប់! ក្រោយមកទៀតគឺពេលដែលខ្ញុំឱបបងឯងនៅមាត់ទ្វារ គេមកទាញកញ្ចឹងកខ្ញុំឲ្យថយក្រោយ ព្រមានខ្ញុំថា មិនអាចឱបមនុស្សប្រុសទៀត!»

មីនដៀងភ្នែក ពិនិត្យពិច័យអាការៈប្អូនទាំងមិនមាត់មិនក។ មេរូនិយាយបន្ថែមញាប់ឡើងៗ៖

«ចំឡែកម្ល៉េះ បើថាខ្ញុំនេះស្រមើស្រមៃ ក៏មិនអាចច្បាស់យ៉ាងនេះដែរ បងឯងគិតមើលមើល៍ ហេតុអីបានជាខ្ញុំខ្លួនឯងអាចបង្កើតសំឡេងស្រមៃឲ្យខ្លួនឯងបាន ថែមទាំងដឹងថា ម្ដាយរបស់មេនសានឹងស្លាប់?»

«ឯងដឹងរឿងហ្នឹងមុនពេលបងប្រាប់មែនអត់?!»

«ចាស មុនពេលខ្ញុំចូលងូតទឹក! មេនសាបាននិយាយទូរសព្ទជាមួយខ្ញុំប្រាប់ថា ម្ដាយគេឈឺ ខ្ញុំថាចង់ទៅមើលមីងដែរ ស្រាប់តែមានសំឡេងបែបនេះនឹងត្រចៀកខ្ញុំ! ខ្ញុំដំបូងមិនសូវចាប់អារម្មណ៍ទេទាល់តែបងឯងខលមកប្រាប់បានខ្ញុំឆ្ងល់»

មីនងក់ក្បាល គេព្យាយាមកាត់សាច់រឿងឱ្យឆាប់ចប់ដោយស្រដីថា៖

«អូខេ បងមិនមែនមិនជឿទេ បងសូមទៅដេកគិតរឿងហ្នឹងសន្សឹមៗសិន បានឆ្លើយឱ្យយោបល់បាន!»

មេរូមិនលែងដៃនៅតែខំនិយាយបន្តថា៖

«ដល់ពេលខ្ញុំចូលបន្ទប់ទឹក ក្នុងកញ្ចក់ចេញរូបមនុស្សប្រុសមានពាក់មកុដម្នាក់ ខ្មៅស្រឹលគ្មានមុខមាត់ទេ! ដំបូងលេចចេញមក ព្រោះជាស្រមោលខ្មៅ ក្រោយមកពេលខ្ញុំស្រែក ក៏ចេញជាមានភ្នែក២គ្រាប់ដូចត្បូងកណ្ដៀងពណ៌ខៀវខ្ចី!»

មីនស្រងូតច្បូតដៃប្អូនចេញ ថយទៅម្ខាងជាមួយភាពងឿងឆ្ងល់ពេញទ្រូង។

មេរូឆ្ងល់ថា ហេតុអ្វីបានជាគេចាប់អារម្មណ៍ចំពោះពាក្យសម្ដីចុងក្រោយនេះ ព្រោះគេកំពុងអង្គុយចុះចុចទូរសព្ទមិនព្រមគេងនោះទេ។

ពេលប្អូនស្រីនៅតែតាមមើលបងប្រុសជានិច្ច នោះនាងឆ្លៀតនិយាយទៀត៖

«មុនពេលបងមីនឡើងមកដល់អាផាតមិន ខ្ញុំយល់សប្ដិឃើញលិចទឹកពាសពេញបន្ទប់! ខ្ញុំប្រាប់ម្ដងរួចហើយ ខ្ញុំក៏គិតថាវាគ្រាន់តែជាការយល់សប្ដិដែរ ចុះម៉េចក៏ស្រោមជើងខ្ញុំទទឹកជោកបាន?»

មីនសម្លឹងប្អូនស្រីពេលឮបែបនេះ រួចឱនធ្វើការលើទូរសព្ទទៀត។ មេរូដកដង្ហើមធំ។

«រូបបែបនេះមែនទេដែលឯងថាឃើញក្នុងកញ្ចក់?!»

នាងបះរោមក្រញាងនៅពេលដែលឃើញរូបភាពនៅក្នុងកញ្ចក់ទូរសព្ទដៃ ដែលបងប្រុសជីដូនមួយក្រោកមកបង្ហាញ។

ជាអ្វីដែលដូចគ្នាបេះបិទនឹងរឿងនាងបានឃើញរហូតដល់សន្លប់។

គឺរូបពាក់កណ្ដាលខ្លួននៃមនុស្សប្រុសខ្មៅស្រឹល គ្មានមុខហើយភ្នែកជាគ្រាប់ត្បូងខៀវ។

មេរ្សរុញទូរសព្ទទៅឲ្យបងវិញទាំងភ័យខ្លាច។ នាងនិយាយប្រាប់បន្ទាន់ថា៖

«រូបនេះឯង ខ្ញុំឃើញម្នាក់នេះច្បាស់តាមកញ្ចក់បន្ទប់ទឹក បងមីនឯងSearchបានមកពីណា?!»

មីនអង្គុយលើគ្រែក្បែរប្អូន ប្អូនក្រោកមកអង្គុយជិត ។ បងប្រុសនិយាយទាំងព្រួយភ័យ៖

«នេះគឺស្ដេចគ្មានច្រមុះមាត់ ដែលគ្រូទើបនឹងបង្ហាញពួកយើងឱ្យសិក្សាកាលពីខែមុន! ព្រះអង្គមាន ភ្នែកមួយគូពណ៌ដូចជាត្បូងដូច្នេះឯង!»

មេរ្សធ្វើមុខស្លេកស្លាំង។